**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ ០១១/២០០៣ កបធ.សជណ រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៣

**ជំរាបមក**

**លោក ឌី តីឡា**

អាស័យដ្ឋានផ្ទះលេខ ៥៤៧ ក្រុមទី ៤ ភូមិដំណាក់ធំ

សង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

**កម្មវត្ថុ** : ប្តឹងបដិសេធសេចក្តីសម្រេចលេខ ០៥/៣២៤/០៣ គ.ជ.ប ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**យោង** : លិខិតរបស់លោក លេខ ពិសេស ត.ក.ខ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៣

តបតាមលិខិតរបស់លោកដូចមានក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសជំរាបលោកថា ក្រុមប្រឹក្សាធម្មនុញ្ញ ពុំអាចទទួលពាក្យបណ្តឹងរបស់លោកយកមកពិនិត្យពិភាក្សាបានទេ ដោយករណីដែលលោកបានលើកឡើង មិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ក្រុមប្រឹក្សាធម្មនុញ្ញទទួលពិនិត្យបានតែករណីដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធមិនព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដូចមានចែងក្នុងមាត្រា ៤២ថ្មី នៃព្រះរាជក្រមនស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

រឿងជម្លោះរវាងលោក និង ឈ្មោះ **ឌី ឈិន** ជារឿងក្តីរដ្ឋប្បវេណី ដែលស្ថិតនៅក្នុងសមត្ថកិច្ចតុលាការតែប៉ុណ្ណោះ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**